ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ ២១៦

ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩

សាលដីកា

លេខ ២៩៦ VIII

ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២១

ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម ៖

១.ឯកឧត្តម [redacted] ជាប្រធាន

២.ឯកឧត្តម [redacted] ជាចៅក្រម

៣.ឯកឧត្តម [redacted] ជាចៅក្រម

៤.ឯកឧត្តម [redacted] ជាចៅក្រម

៥.ឯកឧត្តម [redacted] ជាចៅក្រម

### ចៅក្រមរបាយការណ៍

ឯកឧត្តម [redacted]

### ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted]

### តំណាងមហាអយ្យការ

ឯកឧត្តម [redacted] ជាអគ្គព្រះរាជអាជ្ញារង

### ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ ២៨៤ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] នាង និង ឈ្មោះ [redacted] សារ៉ែន ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៦៣ ក្រII "ញ" ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញ ដែលមាន ៖

-ជនជាប់ចោទ ៖

១-ឈ្មោះ [redacted] ចំរើន ហៅ ណុយ ភេទប្រុស អាយុ១៧ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរសិស្ស ទីកន្លែងកំណើតភូមិសាច់ប៉ូយ ឃុំវត្តគរ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង ទីលំនៅមុនពេល [redacted] សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (ស) នៅលីវ ទោសពីមុនគ្មាន ។ (ក្នុងឃុំ)



Scanned with CamScanner

ជាប់ចោទពីបទ៖ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ២០១៦ ដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៥ ចំណុច១ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២-ឈ្មោះ [redacted] **រ៉ូហ្សា** ហៅ **ស៊ីណា** ហៅ មុំ ភេទស្រី អាយុ ២៤ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរកសិករ ទីកន្លែងកំណើតស្រុកក្រគរ ខេត្តពោធិ៍សាត់ ទីលំនៅមុនពេលឃាត់ខ្លួនមិនពិតប្រាកដ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ប្តីឈ្មោះ [redacted] (លែងលះ) ជានីតិជន ទោសពីមុនធ្លាប់ជាប់ពន្ធនាគារ០៤ខែ ពីបទ រំលោភលើសេចក្តីទុកចិត្ត ។ (ក្នុងឃុំ)

ជាប់ចោទពីបទ៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ២០១៦ ដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ៣ កថាខណ្ឌ៤ និងមាត្រា ៣២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣-ឈ្មោះ [redacted] **នាង** ហៅ [redacted] **វណ្ណដា** ភេទប្រុស កើតឆ្នាំ១៩៦៨ ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរម៉ៅការសំណង់ ទីកន្លែងកំណើតនៅ [redacted] ខេត្តបាត់ដំបង ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន ០២នាក់ ទោសពីមុនធ្លាប់ជាប់ពន្ធនាគារ ២៥ឆ្នាំ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ។ (អ្នកប្តឹងសាទុក្ខ)

. បច្ចុប្បន្នឃុំខ្លួននៅពន្ធនាគារព្រៃស ម១ ។

-មានមេធាវីការពារសិទ្ធិ៖ លោក [redacted] ធីរៈ លោក [redacted] វិបុល និងលោក [redacted] ឫទ្ធី ។

៤-ឈ្មោះ [redacted] **មន្នី** ហៅ **ចែនី** ភេទស្រី អាយុ ៣២ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរនៅផ្ទះ ទីកន្លែងកំណើតនៅភូមិកោះរកាក្នុង ឃុំកោះរការ ស្រុកកំពង់សៀម ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ននៅភូមិទឹក [redacted] ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្តីឈ្មោះ [redacted] វណ្ណដា ហៅ ដា ទោសពីមុនគ្មាន ។ "ក្នុងឃុំ"

៥-ឈ្មោះ [redacted] **លីហៀង** ហៅ **ហៀង** ភេទប្រុស អាយុ ៣៤ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិអូរចំលង់ ឃុំតាសែន ស្រុកកំរៀង ខេត្តបាត់ដំបង សព្វថ្ងៃឃុំខ្លួននៅពន្ធនាគារខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] (លែងលះ) ទោសពីមុនធ្លាប់ជាប់ពន្ធនាគារ ២៥ឆ្នាំ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ។

៦-ឈ្មោះ [redacted] **សាធី** ហៅ **ចាក់** ភេទប្រុស កើតឆ្នាំ១៩៨០ ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរកសិករ ទីកន្លែងកំណើតនៅភូមិសែនពន្លក ឃុំសំរោង ស្រុកទូកមាស ខេត្តកំពត ទីលំនៅមុនពេល [redacted] ខេត្តបាត់ដំបង ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted]



Scanned with CamScanner

[redacted](លែងលះ) ទោសពីមុនធ្លាប់ជាប់ពន្ធនាគារ ២៥ឆ្នាំ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ។ (ក្នុងឃុំ)

៧-ឈ្មោះ [redacted]ហាង ភេទប្រុស អាយុ ២៩ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរកម្មករ ទីកន្លែងកំណើតនៅភូមិក្របីរៀល ឃុំក្របីរៀល ស្រុកពួក ខេត្តសៀមរាប ទីលំនៅមុន[redacted] ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោ[redacted]ស) ម្តាយឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted] (លែងលះ) ទោសពីមុនធ្លាប់ជាប់ពន្ធនាគារ៦ឆ្នាំ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ។ (ក្នុងឃុំ)

៨-ឈ្មោះ [redacted]សារ៉ែន ហៅ ម៉ាច់ ហៅ ឡែន ភេទប្រុស កើតឆ្នាំ១៩៩២ ជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិគោកក្នុង ឃុំកោះរការ ស្រុកកំពង់សៀម ខេត្តកំពង់ចាម ទីលំនៅមុនពេលឃាត់ខ្លួននៅ [redacted] ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន ។ (អ្នកប្តឹងសាទុក្ខ)

.បច្ចុប្បន្នឃុំខ្លួននៅពន្ធនាគារខេត្តបន្ទាយមានជ័យ

-មានមេធាវីការពារសិទ្ធិ៖ លោក[redacted] ធីរ: លោ[redacted] វិបុល និងលោក[redacted]ម៉ូរ៉ា ។

៩-ឈ្មោះ [redacted] ណារ៉ែន ភេទស្រី កើតឆ្នាំ១៩៨៩ ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរនំស្ប៉ត ទីកន្លែងកំណើតភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល ទីលំនៅ[redacted] ដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល ឪពុកឈ្មោះ [redacted](រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ជានីតិជនទោសពីមុនគ្មាន ។ (ក្រៅឃុំ)

ជាប់ចោទពីបទ៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងសំអាតប្រាក់** ប្រព្រឹត្តនៅចំណុចពន្ធនាគារខេត្តបន្ទាយមានជ័យ និងចំណុចបន្ទប់ជួលស្ថិតនៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ២០១៦ ដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៦ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៥ ចំណុច១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ៤០៤ និងមាត្រា ៤០៦ នៃក្រមព្រហ្មទណ្ឌ ។

១០-ឈ្មោះ [redacted]សីហា ហៅ គិត ភេទប្រុស កើតឆ្នាំ១៩៨២ ជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើត និងទីលំនៅមុនពេលឃាត់[redacted] ខេត្តកំពង់ធំ ឪពុកឈ្មោះ [redacted](រ) ម្តាយឈ្មោះ[redacted] (រ) ទោសពីមុនធ្លាប់ជាប់ពន្ធនាគារ ០៦ឆ្នាំ ។ (ក្នុងឃុំ)

ជាប់ចោទពីបទ៖ **សមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចពន្ធនាគារខេត្តបន្ទាយមានជ័យ និងចំណុចបន្ទប់ជួលស្ថិតនៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ២០១៦ ដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៥ ចំណុច១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។



Scanned with CamScanner

អំពីអង្គហេតុ

កាលពីថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៦ វេលាម៉ោង ១៥ និង ៤៥នាទី ស្ថិតនៅចំណុចភូមិភ្នំកន្ទួត សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ដោយអនុវត្តតាមវិធានញុះញង់ឱ្យលក់ដោយខុសច្បាប់នូវសារធាតុញៀន កម្លាំងការិយាល័យបទល្មើសគ្រឿងញៀន បានចុះធ្វើប្រតិបត្តិការបង្ក្រាបករណីជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដោយធ្វើការឃាត់ខ្លួនជនសង្ស័យ០១នាក់ ឈ្មោះ [redacted] ចំរើន ហៅ ណុយ ភេទប្រុស អាយុ១៧ឆ្នាំ តាមការស្តាប់ចម្លើយ និងសហការចង្អុលបង្ហាញពីជនសង្ស័យឈ្មោះ [redacted] ចំរើន ម៉ោង ១៨ និង៣០នាទី នៅចំណុចភូមិកកោះ ឃុំអូរតាគី ស្រុកថ្មគោល ខេត្តបាត់ដំបង កម្លាំងយើងសហការជាមួយកម្លាំងសមត្ថកិច្ចកងរាជអាវុធហត្ថខេត្តបាត់ដំបង បានបន្តប្រតិបត្តិការបង្ក្រាបឃាត់ខ្លួនជនសង្ស័យបានចំនួន ០១នាក់ទៀត ដែលមានឈ្មោះ [redacted] វ៉ូហ្សា ភេទស្រី អាយុ២៤ឆ្នាំ ហើយឈ្មោះ [redacted] វ៉ូហ្សា បានសហការជាមួយកម្លាំងសមត្ថកិច្ចកងរាជអាវុធហត្ថ រួចបន្តការឃាត់ខ្លួនមេក្លោងធំដទៃទៀត ដែលជាទណ្ឌិតនៅក្នុងពន្ធនាគារខេត្តបន្ទាយមានជ័យជាបន្តបន្ទាប់បានចំនួន០៧នាក់ទៀត ដែលមានឈ្មោះ [redacted] មន្នី ភេទស្រី អាយុ៣២ឆ្នាំ, ឈ្មោះ [redacted] សារ៉េន ភេទប្រុស អាយុ២៥ឆ្នាំ, ឈ្មោ[redacted]នាង ភេទប្រុស អាយុ៥០ឆ្នាំ, ឈ្មោ[redacted]លីហៀង ភេទប្រុស អាយុ៣៣ឆ្នាំ, ឈ្មោះ [redacted] ហេង ភេទប្រុស អាយុ២៨ឆ្នាំ, ឈ្មោះ[redacted]សីហា ភេទប្រុស អាយុ៣៥ឆ្នាំ និងឈ្មោះ [redacted] សារី ភេទប្រុស អាយុ៣៦ឆ្នាំ ។ បន្ទាប់មកនៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦ សមត្ថកិច្ចបានចុះទៅទីតាំងអគារជួលដែលមាន១៨បន្ទប់ ស្ថិតនៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ជាកម្មសិទ្ធិរបស់ឈ្មោ[redacted]នាង ហៅ[redacted] វណ្ណដា និងប្រពន្ធឈ្មោ[redacted]មន្នី បានធ្វើការឆែកឆេរបន្ទប់ស្នាក់នៅរបស់ឈ្មោះ [redacted] មន្នី និងឆែកឆេរបន្ទប់ស្នាក់នៅរបស់ឈ្មោះ [redacted] ណារ៉េន ភេទស្រី អាយុ២៤ឆ្នាំ រឹបអូសបានវត្ថុតាងមួយចំនួនធំ ហើយសមត្ថកិច្ចបានសម្រេចបិទទីតាំងអគារជួលទាំងមូលតែម្តង ។ អគារជួល និងវត្ថុតាងដែលចាប់យកទាំងអស់ គឺបានមកពីអំពើល្មើសក្នុងបទល្មើសគ្រឿងញៀនដើម្បីសម្អាតប្រាក់ ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ០៧ (ឧ) ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៨ របស់សភាព្រហ្មទណ្ឌសាលាដំបូងខេត្តបន្ទាយមានជ័យ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

ចំពោះមុខជនជាប់ចោទឈ្មោ[redacted]មន្នី, ឈ្មោះ [redacted]សារ៉េន, ឈ្មោ[redacted]សារី, ឈ្មោះ [redacted] ហេង ឈ្មោ[redacted] លីហៀង, ឈ្មោ[redacted] វ៉ូហ្សា, ឈ្មោះ [redacted] ចំរើន និងឈ្មោះ [redacted]សីហា កំបាំងមុខឈ្មោះ [redacted] នាង ឈ្មោ[redacted] ណារ៉េន

១-ផ្តន្ទាទោសលើជនជាប់ចោទដូចខាងក្រោម៖

ក.ឈ្មោះ [redacted] ចំរើន ហៅ ណុយ ភេទប្រុស អាយុ១៧ឆ្នាំ (អត្តសញ្ញាណខាងលើ)

ដាក់ពន្ធនាគារកំណត់ចំនួន ០២ឆ្នាំ ០៦ខែ ពីបទ៖ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ២០១៦ ដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៥ ចំណុច១ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ ។



Scanned with CamScanner

ខ.ឈ្មោះ [redacted]វុំហ្គា ហៅ ស៊ីណា ហៅ មុំ ភេទស្រី អាយុ ២៤ឆ្នាំ (អត្តសញ្ញាណខាងលើ)

ដាក់ពន្ធនាគារកំណត់ចំនួន ០១ឆ្នាំ ០៦ខែ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ២០១៦ ដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ៣ កថាខណ្ឌ៤ និងមាត្រា ៣២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

គ.ឈ្មោះ [redacted]នាង ហៅ [redacted]វណ្ណដា ភេទប្រុស កើតឆ្នាំ១៩៦៨ (អត្តសញ្ញាណខាងលើ)

ដាក់ពន្ធនាគារកំណត់ចំនួន ០៨ឆ្នាំ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងសំអាតប្រាក់ ប្រព្រឹត្តនៅចំណុចពន្ធនាគារខេត្តបន្ទាយមានជ័យ និងចំណុចបន្ទប់ជួលស្ថិតនៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ២០១៦ ដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៦ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៥ ចំណុច១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ៤០៤ និងមាត្រា ៤០៦ នៃក្រមព្រហ្មទណ្ឌ ។

ឃ.ឈ្មោះ [redacted]មន្នី ហៅ ចៃនី ភេទស្រី អាយុ ៣២ឆ្នាំ (អត្តសញ្ញាណខាងលើ)

ង.ឈ្មោះ [redacted]បីហៀង ហៅ ហៀង ភេទប្រុស អាយុ ៣៤ឆ្នាំ (អត្តសញ្ញាណខាងលើ)

ច.ឈ្មោះ [redacted]សារី ហៅ បាក់ ភេទប្រុស កើតឆ្នាំ១៩៨០ (អត្តសញ្ញាណខាងលើ)

ឆ.ឈ្មោះ [redacted]ហេង ភេទប្រុស អាយុ ២៩ឆ្នាំ (អត្តសញ្ញាណខាងលើ)

ជ.ឈ្មោះ [redacted]សារ៉ែន ហៅ ម៉ាប់ ហៅ ឡែន ភេទប្រុស កើតឆ្នាំ១៩៩២ (អត្តសញ្ញាណខាងលើ)

ឈ.ឈ្មោះ [redacted] ណារ៉ែន ភេទស្រី កើតឆ្នាំ១៩៨៩ (អត្តសញ្ញាណខាងលើ)

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់០៥ឆ្នាំ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងសំអាតប្រាក់ ប្រព្រឹត្តនៅចំណុចពន្ធនាគារខេត្តបន្ទាយមានជ័យ និងចំណុចបន្ទប់ជួលស្ថិតនៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ២០១៦ ដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៥ ចំណុច១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ៤០៤ និងមាត្រា ៤០៦ នៃក្រមព្រហ្មទណ្ឌ ។

ញ.ឈ្មោះ [redacted]សីហា ហៅ គិត ភេទប្រុស កើតឆ្នាំ១៩៨២ (អត្តសញ្ញាណខាងលើ)

ដាក់ពន្ធនាគារកំណត់ ០៥ឆ្នាំ ពីបទ សមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចពន្ធនាគារខេត្តបន្ទាយមានជ័យ និងចំណុចបន្ទប់ជួលស្ថិតនៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ២០១៦ ដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៥ ចំណុច១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ ។



Scanned with CamScanner

២-រឹបអូសទ្រព្យសម្បត្តិដី និងផ្ទះ ជាអគារបន្ទប់ជួលរបស់ឈ្មោះ [redacted] នាង និងឈ្មោះ [redacted] មន្នី ស្ថិតនៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ដែលបានបង្កកតាមដីកាបង្កកទ្រព្យសម្បត្តិលេខ ១៩០៣ ពស.ព្រទ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបន្ទាយមានជ័យ។

៣-រឹបអូសនូវវត្ថុតាងជាថ្នាំញៀន ដូចក្នុងកំណត់ហេតុដែលដកហូតបានពីឈ្មោះ [redacted] ចំរើន និងឈ្មោះ [redacted] ហ្វា ។

៤-រឹបអូសនូវសម្ភារៈរួមមាន៖ ជញ្ជីងថ្លឹងគ្រឿងញៀន, រថយន្តម៉ាកតូយ៉ូតាកូរ៉ូឡា ឆ្នាំ១៩៩៤ ពណ៌បៃតងចាស់, ទូរស័ព្ទដៃ, ម៉ាស៊ីន MP4, កូនថង់សម្រាប់ច្រកគ្រឿងញៀន និងសម្ភារៈសម្រាប់ជក់គ្រឿងញៀនដូចមានក្នុងកំណត់ហេតុដែលសមត្ថកិច្ចដកហូតបានពីឈ្មោះ [redacted] មន្នី, ឈ្មោះ [redacted] សារ៉េន, ឈ្មោ[redacted] សីហា, ឈ្មោះ[redacted]នាង និងឈ្មោះ[redacted] លីហៀង ។

៥-បញ្ឈប់អានុភាពដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ២៤៨ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៦ លើឈ្មោ[redacted] ណារ៉េន របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបន្ទាយមានជ័យ ។

៦-បង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] ណារ៉េន ភេទស្រី កើតឆ្នាំ១៩៨៩ (អត្តសញ្ញាណខាងលើ) តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៧ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៨ នៅសាលាដំបូងខេត្តបន្ទាយមានជ័យ ។ ទុកសិទ្ធិឱ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ១៩ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ[redacted] នាង ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ០៧ (ឆ) ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៨ របស់សភាព្រហ្មទណ្ឌសាលាដំបូងខេត្តបន្ទាយមានជ័យ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញ បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] សារ៉េន [redacted]មន្នី,[redacted] សីហា,[redacted]លីហៀង,[redacted] ចេង និងឈ្មោះ[redacted]សារី ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ០៧ (ឆ) ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៨ របស់សភាព្រហ្មទណ្ឌសាលាដំបូងខេត្តបន្ទាយមានជ័យ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ៦៣ ក្រII "ញ" ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-ក.ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោ[redacted] នាង ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

ខ.ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] សារ៉េន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ។

គ.ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ[redacted]មន្នី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ។



Scanned with CamScanner

ឃ.ទទួលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] សីហា ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

ង.ទទួលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] លីហៀង ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

ច.ទទួលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] ហេង ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

ឆ.ទទួលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោ[redacted]សារី ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ០៧ (ឆ) ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ទុកជាបានការ លើកលែងតែចំណុចមួយចំនួនដូចខាងក្រោម៖

ក.ចំណុចទី១ "ង, ច, ឆ និង ញ" ត្រូវបដិសេធចោល និង សម្រេចឲ្យឈ្មោះ [redacted] លីហៀង ឈ្មោះ [redacted] សារី និងឈ្មោះ [redacted] ហេង រួចខ្លួនពីបទចោទប្រកាន់គឺបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និង បទសម្អាតប្រាក់ ប្រព្រឹត្តនៅចំណុចពន្ធនាគាខេត្តបន្ទាយមានជ័យ និងចំណុចបន្ទប់ជួលស្ថិតនៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីកំឡុងឆ្នាំ២០១៦ ដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៣ និង កថាខណ្ឌ៥ ចំណុច១ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន និង មាត្រា ៤០៤ និង មាត្រា ៤០៦ នៃក្រមព្រហ្មទណ្ឌ និងឈ្មោះ [redacted] សីហា រួចខ្លួនពីបទចោទប្រកាន់គឺបទ សមគំនិតជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចពន្ធនាគារខេត្តបន្ទាយមានជ័យ និងចំណុចបន្ទប់ជួលស្ថិតនៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ២០១៦ ដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៣ និង កថាខណ្ឌ៥ ចំណុច១ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន និង មាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ។

ខ.ចំណុចទី១ "ឃ" ស្ដីពីការផ្ដន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] មន្នី ដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងបទ សម្អាតប្រាក់ ត្រូវសម្រេចបដិសេធចោលនូវបទចោទប្រកាន់ គឺបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងសម្រេចឲ្យជនជាប់ចោទឈ្មោះ [redacted] មន្នី រួចខ្លួនពីបទចោទប្រកាន់ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចពន្ធនាគារខេត្តបន្ទាយមានជ័យ និងចំណុចបន្ទប់ជួលស្ថិតនៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ២០១៦ ដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៥ ចំណុច១ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។



Scanned with CamScanner

គ.ចំណុចទី១ "ជ" ស្តីពីការផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ[redacted]សារ៉េន ដាក់ពន្ធនាគារកំណត់៥ឆ្នាំ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងបទ សម្អាតប្រាក់ ត្រូវសម្រេចបដិសេធចោលនូវបទចោទប្រកាន់ គឺបទ សម្អាតប្រាក់ និងសម្រេចឲ្យជនជាប់ចោទ ឈ្មោ[redacted]សារ៉េន រួចខ្លួនពីបទចោទប្រកាន់ គឺបទ សម្អាតប្រាក់ ប្រព្រឹត្តនៅចំណុចពន្ធនាគារខេត្តបន្ទាយមានជ័យ និងចំណុចបន្ទប់ជួលស្ថិតនៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីកំឡុងឆ្នាំ២០១៦ ដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៦ បទល្មើសមានចែង និងផ្តន្ទាទោសតាមមាត្រា ៤០៤ មាត្រា ៤០៦ នៃក្រមព្រហ្មទណ្ឌ ។

៣-បង្គាប់ឲ្យដោះលែងឈ្មោះ[redacted] ហេង ឈ្មោ[redacted]លីហៀង និងឈ្មោះ[redacted] សារី ដែលជាប់ចោទពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងបទ សម្អាតប្រាក់ ប្រព្រឹត្តនៅចំណុចពន្ធនាគារខេត្តបន្ទាយមានជ័យ និងចំណុចបន្ទប់ជួលស្ថិតនៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីកំឡុងឆ្នាំ២០១៦ ដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៦ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ៣ និង កថាខណ្ឌ៥ ចំណុច១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ៤០៤ និងមាត្រា ៤០៦ នៃក្រមព្រហ្មទណ្ឌ និងឈ្មោះ[redacted]សីហា ពីបទ សមគំនិតជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចពន្ធនាគារខេត្តបន្ទាយមានជ័យ និងចំណុចបន្ទប់ជួលស្ថិតនៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ក្រុងសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីអំឡុងឆ្នាំ២០១៦ ដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៥ ចំណុច១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌជាបន្ទាន់ កាលបើឈ្មោះខាងលើមិនត្រូវបានឃុំខ្លួនពីបទល្មើសអ្វីផ្សេងទៀតទេ។

៤-បន្តការឃុំខ្លួនជាបណ្តោះអាសន្នលើឈ្មោ[redacted]នាង ឈ្មោះ[redacted] មុន្នី និងឈ្មោ[redacted]សារ៉េន តាមនីតិវិធីច្បាប់។

៥-សាលដីកានេះប្រកាសជាសាធារណៈនៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទឈ្មោះ[redacted]នាង, ឈ្មោ[redacted]សារ៉េន,ឈ្មោះ[redacted]លីហៀង ឈ្មោ[redacted]ហេង និងឈ្មោះ[redacted]សារី កំបាំងមុខឈ្មោះ[redacted]ន្នី និងឈ្មោះ[redacted]សីហា ទុកសិទ្ធិឲ្យប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញ បណ្តឹងសាទុក្ខលេខ ២៨៤ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោ[redacted] នាង និងឈ្មោះ [redacted] សារ៉េន ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ៦៣ ក្រII "ញ" ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

## នាពេលសវនាការ

-ចៅក្រមបានអានរបាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូល បានធ្វើសេចក្តីសន្និដ្ឋានថា៖ បណ្តឹងសាទុក្ខរបស់ជនជាប់ចោទឈ្មោ[redacted]នាង, [redacted] មន្នី និងឈ្មោ[redacted]សារ៉េន មិនមានមូលហេតុដូចក្នុងមាត្រា ៤១៩ នៃក្រមនីតិវិធី



Scanned with CamScanner

ព្រហ្មទណ្ឌឡើយ ។ តំណាងមហាអយ្យការអមតុលាការកំពូល យល់ព្រមក្នុងការយល់ឃើញរបស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ ដែលមានភស្តុតាងដាក់បន្ទុកត្រឹមត្រូវតាមច្បាប់ ។

ហេតុដូច្នេះ សូមក្រុមប្រឹក្សាជំនុំជម្រះសម្រេចតម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៦៣ ក្រII "ញ" ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ទុកជាបានការដដែល ។

+លោក [redacted] ម្វ៉ា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា៖ កូនក្តីរបស់ខ្លួនពិតជាបានប្រព្រឹត្តបទល្មើសពាក់ព័ន្ធនឹងការជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដូចការចោទប្រកាន់របស់តំណាងអយ្យការមែន ចំពោះបទល្មើសសំអាតប្រាក់ ខ្លួនសុំឱ្យតុលាការសម្រេច ពិនិត្យពិចារណា រកយុត្តិធម៌ឱ្យកូនក្តីខ្លួន ដោយហេតុថា ការចោទប្រកាន់កូនក្តីខ្លួនពីបទ សំអាតប្រាក់នោះពុំមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់នោះទេ ព្រោះថា ប្រាក់ដែលកូនក្តីខ្លួនបានសាងសង់ផ្ទះជួលនោះ គឺបានមកពីការលក់ដីជាមួយប្រពន្ធមុនរបស់គាត់នៅស្រុកកំរៀង ខេត្តបាត់ដំបង កាលពីឆ្នាំ២០១៣ មិនមែនជាប្រាក់បានពីការជួញដូរគ្រឿងញៀនទេ ប្រសិនបើតុលាការយល់ឃើញថា ជនជាប់ចោទពិតជាបានប្រព្រឹត្តអំពើសំអាតប្រាក់មែន នោះផ្ទះជួលរបស់កូនក្តីខ្លួននឹងត្រូវរឹបអូសជាសម្បត្តិរដ្ឋ ដែលធ្វើឱ្យប៉ះពាល់ដល់ជីវភាពរស់នៅរបស់ក្រុមគ្រួសារគាត់យ៉ាងខ្លាំង ។

សំណូមពរ សូមក្រុមប្រឹក្សាជំនុំជម្រះសម្រេចបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនផង ។

+ជនជាប់ចោទឈ្មោះ [redacted] សារ៉េន បានឆ្លើយថា៖ ខ្លួនទទួលស្គាល់ថា បានប្រព្រឹត្តអំពើជួញដូរគ្រឿងញៀនពិតមែន ចំពោះការចោទប្រកាន់របស់តុលាការដែលថា ខ្លួនលាងលុយកខ្វក់នោះគឺមិនពិតទេ ខ្លួនពុំបានយកប្រាក់ពីការជួញដូរគ្រឿងញៀនមកធ្វើផ្ទះជួលទេ គឺខ្លួនបានប្រាក់ពីការលក់ដីនៅខេត្តបាត់ដំបង ។

សំណូមពរ សូមតុលាការជួយបន្ធូរបន្ថយទោសដល់ខ្លួនផង ។

+ជនជាប់ចោទឈ្មោះ [redacted] នាង បានឆ្លើយថា៖ បងប្រុសរបស់ខ្លួនមិនបានប្រព្រឹត្តអំពើសំអាតប្រាក់ដើម្បីយកមកធ្វើផ្ទះជួលនោះទេ ។

សំណូមពរ សុំតុលាការជួយរកយុត្តិធម៌ និងបន្ធូរបន្ថយទោសដល់បងប្រុសខ្លួនផង ។

+តំណាងមហាអយ្យការអមតុលាការកំពូលបានធ្វើសេចក្តីសន្និដ្ឋានបន្ថែមថា៖ គោលការណ៍ចោទប្រកាន់ពីបទល្មើសសំអាតប្រាក់ កាលណាបទល្មើសនោះជាប្រភេទបទល្មើស គ្រឿងញៀន ជួញដូរសត្វព្រៃ ស៊ីសំណូក ជួញដូរមនុស្ស គឺចាំបាច់ធ្វើការចោទប្រកាន់ពីបទសំអាតប្រាក់ មានន័យថា ប្រសិនបើមិនចោទប្រកាន់ពីបទសំអាតប្រាក់ទេ ជនល្មើស ឬឧក្រិដ្ឋជនអាចប្រើប្រាស់ប្រាក់ខុសច្បាប់ទាំងនោះ ដើម្បីប្រព្រឹត្តបទល្មើសតទៅទៀត ។ អំបាញ់មិញជនជាប់ចោទបានឆ្លើយទទួលស្គាល់អំពើប្រព្រឹត្តរបស់ខ្លួនពីបទ ជួញដូរគ្រឿនញៀន ដោយឡែកចំពោះបទល្មើសសំអាតប្រាក់ជនជាប់ចោទបានធ្វើការពារ ប៉ុន្តែតំណាងមហាអយ្យការយល់ឃើញថា ការសម្រេចរបស់សាលាឧទ្ធរណ៍ត្រឹមត្រូវតាមច្បាប់ហើយ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ



Scanned with CamScanner

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ និងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការកំពូល

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ២៨៦ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted]នាង និងឈ្មោះ[redacted] សារ៉ែន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបានតាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-យល់ឃើញថា នាពេលសវនាការជនជាប់ចោទ ក៏ដូចជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានទទួលស្គាល់ថា កូនក្តីរបស់ខ្លួនពិតជាបានប្រព្រឹត្តបទល្មើសពាក់ព័ន្ធនឹងការជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដូចការចោទប្រកាន់របស់តំណាងអយ្យការមែន ប៉ុន្តែបទល្មើសមួយទៀតគឺ បទល្មើសសំអាតប្រាក់ ខ្លួនសុំឱ្យតុលាការសម្រេច ពិនិត្យ ពិចារណា រកយុត្តិធម៌ឱ្យកូនក្តីខ្លួន ដោយហេតុថា ការចោទប្រកាន់កូនក្តីខ្លួន ពីបទ សំអាតប្រាក់នោះពុំមានភស្តុតាងគ្រប់គ្រាន់ទេ ពីព្រោះថា ប្រាក់ដែលកូនក្តីខ្លួនសាងសង់ផ្ទះជួល គឺបានមកពីការលក់ដីនៅស្រុកកំរៀង ខេត្តបាត់ដំបង ក្នុងឆ្នាំ២០១៣ មិនមែនប្រាក់បានមកពីការជួញដូរគ្រឿងញៀនទេ នោះតុលាការកំពូលពុំអាចពិចារណាបានទេ ពីព្រោះថា អង្គហេតុពាក់ព័ន្ធនឹងបទសំអាតប្រាក់ ដែលជនជាប់ចោទ ក៏ដូចជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានលើកឡើងនាពេលសវនាការនេះ គឺជាអង្គហេតុដដែលៗ ដែលជនជាប់ចោទបានលើកឡើងនាពេលសវនាការនៃតុលាការអង្គសេចក្តី ហើយតុលាការអង្គសេចក្តីក៏បានពិនិត្យពិចារណា ដូចមាននៅក្នុងចំណុចទី២ នៃសំអាងហេតុ នៃសាលដីកាព្រហ្មទណ្ឌលេខ ៦៣ ក្រII "ញ" ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ភ្នំពេញ រួចរាល់ត្រឹមត្រូវអស់ហើយៗតុលាការកំពូលយល់ស្របនឹងសំអាងហេតុនេះ ដោយពុំចាំបាច់សរសេរជាថ្មីនូវសំអាងហេតុទៀតទេ ។ ដូច្នេះ សេចក្តីសម្រេចរបស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ មានសំអាងហេតុ និងគតិច្បាប់ត្រឹមត្រូវ។

៣-យល់ឃើញថា បណ្តឹងសាទុក្ខរបស់ជនជាប់ចោទខាងលើ ពុំមានមូលហេតុសមស្របតាមមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌទេ ។

៤-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៦៣ ក្រII "ញ" ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេចមកនេះ ត្រឹមត្រូវតាមគតិច្បាប់ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១-បដិសេធបណ្តឹងសាទុក្ខលេខ ២៨៦ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] នាង និងឈ្មោះ[redacted]សារ៉ែន ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៦៣ ក្រII "ញ" ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ភ្នំពេញ ទុកជាបានការពេញទាំងមូល ។



Scanned with CamScanner

៣-សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១ ។

| | | |
|---|---|---|
| -ឯកឧត្តម | [redacted] | ជាប្រធាន |
| -ឯកឧត្តម | [redacted] | ជាចៅក្រម |
| -ឯកឧត្តម | [redacted] | ជាចៅក្រម |
| -ឯកឧត្តម | [redacted] | ជាចៅក្រម |
| -ឯកឧត្តម | [redacted] | ជាចៅក្រម |
| -លោកស្រី | [redacted] | ជាក្រឡាបញ្ជី |

---

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។**

ថ្ងៃចន្ទ ១៤កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

ថ្ងៃចន្ទ ១៤កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]



Scanned with CamScanner